លេខ ១១ ខែ វិច្ឆិកា ឆ្នាំ១៩៩០

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រឹត្យ-ច្បាប់
- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ
- សារាចរណែនាំ

ផ្សាយចេញពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីជារៀងរាល់ខែ

មាតិកា

I – រដ្ឋសភា

ច្បាប់

០៦ - ១១ - ៧០ ច្បាប់ស្ដីពីការលុបចោលសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង សាធារណរដ្ឋប្រជាធិបតេយ្យ-អាល្លឺម៉ង់ ២៨៥

II – ក្រុមប្រឹក្សារដ្ឋ

១ – ក្រឹត្យ

០៦ - ១១ - ៧០ ក្រឹត្យលេខ ៦៨ ក្រ ស្ដីពីការលើកលែងទោស និងបន្ថយទោសអោយទណ្ឌិត ២៨៩

១៣ - ១១ - ៧០ ក្រឹត្យលេខ ៨១ ក្រ ប្រកាសអោយប្រើច្បាប់ស្ដីពីការលុបចោលសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ២៩២

១៣ - ១១ - ៧០ ក្រឹត្យលេខ ៨២ ក្រ ស្ដីពីការសំរួលការកិច្ចសមមិត្តប្រធាន និងអនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី តែងតាំង និងសោយរដ្ឋមន្ត្រី ២៩៧

២៥ - ១១ - ៧០ ក្រឹត្យលេខ ៨៥ ក្រ ស្ដីពីការតែងតាំងជាអនុរដ្ឋមន្ត្រីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ២៩៨

២៥ - ១១ - ៧០ ក្រឹត្យលេខ ៨៦ ក្រ ស្ដីពីការតែងតាំងជាអនុរដ្ឋមន្ត្រីក្រសួងការបរទេស. ២៩៩

III – ក្រុមប្រឹក្សារដ្ឋមន្ត្រី

១ – អនុក្រឹត្យ

១៣ - ១១ - ៧០ អនុក្រឹត្យលេខ ២៨ អនក្រ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានចំការកៅស៊ូ ៣០១

២២ - ១១ - ៧០ អនុក្រឹត្យលេខ ២៩ អនក្រ ស្ដីពីសត្តឃាតដ្ឋាន និងកន្លែងពិឃាតសត្វ ៣០៤

២ – សេចក្តីសំរេច

១៩ - ១១ - ៥៩ សេចក្តីសំរេចលេខ ១៨៦ សសរ ស្តីពីថ្លៃលក់ថាមពលអគ្គិសនី និងទឹក ២៩៤

១៩ - ១១ - ៥០ សេចក្តីសំរេចលេខ ១៨៧ សសរ ស្តីពីថ្លៃទិញឈើខ្លុញឆ្នាំ ១៩៥០-៥១ ២៩៦

១៩ - ១១ - ៥០ សេចក្តីសំរេចលេខ ១៥៨ សសរ ស្តីពីបាលានុក្រមគ្រប់គ្រងថ្លៃ ២៩៨

១៦ - ១១ - ៥០ សេចក្តីសំរេចលេខ ១៦៣ សសរ ស្តីពីថ្លៃលក់ប្រេងឥន្ធនៈ ៣០៤

៣ – សេចក្តីជូនដំណឹង

១៥ - ១១ - ៥០ សេចក្តីជូនដំណឹងលេខ ៤៩ សជណ ស្តីពីការអនុវត្តគោលនយោបាយ ចំពោះគ្រួសារជនពលី ទាហាន ជនពិការ និងគ្រួសារកងទ័ព ៣០៦

I – រដ្ឋសភា

ច្បាប់

ស្តីពីការលុបចោល សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ និង អនុសញ្ញាកុងស៊ុល រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់

មាត្រា ១ ត្រូវទុកជានិរាករណ៍ សន្ធិសញ្ញាមិត្តភាព និង សហប្រតិបត្តិការរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ដែលបានចុះហត្ថលេខាដោយភាគីជាន់ខ្ពស់ទាំង ២ កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ១៩៨០ ។

មាត្រា ២ ត្រូវទុកជានិរាករណ៍អនុសញ្ញាកុងស៊ុល រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ដែលបានចុះហត្ថលេខាដោយភាគីជាន់ខ្ពស់ទាំង ២ កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៨០ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃ រដ្ឋកម្ពុជា អនុម័តនៅថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ១៩៩០

ជ.រដ្ឋសភា

ប្រធាន

ហត្ថលេខានិង ត្រា

ជា ស៊ីម

II– ក្រុមប្រឹក្សារដ្ឋ

ក្រឹត្យ

ក្រឹត្យលេខ ៦៨ ក្រ

ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា

– បានឃើញមាត្រា ៦០ ចំណុច ១១ នៃរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញក្រឹត្យ-ច្បាប់លេខ ០៥ ក្រ.ច ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៨១ ស្តីពីការចាត់តាំងតុលាការយោធា

បានឃើញក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីលក្ខខណ្ឌសំរាប់លើកលែងទោស ឬ បន្ធូរទោសអោយទណ្ឌិត

– ក្រោយពីបានពិនិត្យយោបល់របស់រដ្ឋមន្ត្រី ក្រសួងការពារប្រទេស និង សំណុំរឿងរបស់ទណ្ឌិត ២៤ រូប របស់តុលាការយោធា

– យោងកំណត់ហេតុនៃសម័យប្រជុំសាមញ្ញក្រុមប្រឹក្សារដ្ឋ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ១៩៩០

– ដើម្បីអបអរសាទរក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិថ្ងៃទី ១៤ ខែមេសាឆ្នាំ១៩៩០

សំរេច

មាត្រា ១.– ត្រូវបានលើកលែងទោសអោយទណ្ឌិតចំនួន ៤ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនល្អប្រសើរ ដូចមានរាយឈ្មោះខាងក្រោម :

១ – ទណ្ឌិតឈ្មោះ ឈ សុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមសំណាងសាលក្រមលេខ ១៨ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៨៥ របស់តុលាការយោធា ។

២– ទណ្ឌិតឈ្មោះ មិន សារ៉ាន់ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ២៥ ខែមីនាឆ្នាំ ១៩៨៥ របស់តុលាការយោធា ។

៣– ទណ្ឌិតឈ្មោះ គីម សាខា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ១៩៨២ របស់តុលាការយោធា ។

៤– ទណ្ឌិតឈ្មោះ ឈុត រ៉ាទី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ១៩៨២ របស់តុលាការយោធា ។

មាត្រា ២.– ត្រូវបានបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ១២ ខែ អោយទណ្ឌិតចំនួន ៨ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនល្អ ក្នុងរយៈកាលកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១– ទណ្ឌិតឈ្មោះ អ៊ុង សំបូរ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ៦ ខែ មេសាឆ្នាំ ១៩៨៣ របស់តុលាការយោធា ។

២– ទណ្ឌិតឈ្មោះ សន ភឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៨៣ របស់តុលាការយោធា។

៣– ទណ្ឌិតឈ្មោះ គីម ឈឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៨៣ របស់តុលាការយោធា ។

៤– ទណ្ឌិតឈ្មោះ សាន់ ធឿន ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៨១ របស់តុលាការយោធា។

៥– ទណ្ឌិតឈ្មោះ ពេជ្រ ភឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៨២ របស់តុលាការយោធា។

៦– ទណ្ឌិតឈ្មោះ ស្រី ខ្មៅ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៨៣ របស់តុលាការយោធា ។

៧– ទណ្ឌិតឈ្មោះ ម៉ិត ខន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៨៣ របស់តុលាការយោធា។

៨– ទណ្ឌិតឈ្មោះ ផាន់ ស៊ីផាត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៨៣ របស់តុលាការយោធា។

មាត្រា ៣.– ត្រូវបានបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៩ ខែ អោយទណ្ឌិតចំនួន

៨ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនល្អក្នុងរយៈកាលកន្លងមក ដូចមានរាយឈ្មោះខាងក្រោម

១– ទណ្ឌិតឈ្មោះ មិន រុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៨៧ របស់តុលាការយោធា ។

២– ទណ្ឌិតឈ្មោះ មាស ភាព ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨១ របស់តុលាការយោធា។

៣– ទណ្ឌិតឈ្មោះ ស៊ឹម សម្បត្តិ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៨២ របស់តុលាការយោធា។

៤– ទណ្ឌិតឈ្មោះ ងឹម សម្បត្តិ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៨៥ របស់តុលាការយោធា ។

៥– ទណ្ឌិតឈ្មោះ ពេជ្យ ឆន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៨២ របស់តុលាការយោធា។

៦– ទណ្ឌិតឈ្មោះ អ៊ិន ថា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៨៦ របស់តុលាការយោធា ។

៧– ទណ្ឌិតឈ្មោះ ណុប រតនៈ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៨២ របស់តុលាការយោធា។

៨– ទណ្ឌិតឈ្មោះ អ៊ុំ សម្បត្តិ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៨៦ របស់តុលាការយោធា ។

មាត្រា ៤.– ត្រូវបានបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៦ ខែ ដោយទណ្ឌិតចំនួន ៣ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនល្អក្នុងរយៈកាលកន្លងមក ដូចមានរាយឈ្មោះខាងក្រោម៖

១– ទណ្ឌិតឈ្មោះ គង់ ចាន់ហៀន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២៩៨៥ របស់តុលាការយោធា ។

២– ទណ្ឌិតឈ្មោះ សុខ សុវណ្ណ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៨៥ របស់តុលាការយោធា។

៣– ទណ្ឌិតឈ្មោះ ប៊ូ លាវ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៦ របស់តុលាការយោធា ។

មាត្រា ៥.– ការលើកលែងទោសដោយទណ្ឌិតដែលបានប្រព្រឹត្តបទល្មើសព្រហ្ម

ទណ្ឌសាមញ្ញ ដូចមានរាយឈ្មោះក្នុងមាត្រា ១ ពុំមានអានុភាពធ្វើអោយចំះពាល់ដល់ការសំរេចពីសំណាងរដ្ឋប្បវេណីឡើយ ។

មាត្រា ៦.— ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ១៩៩០

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា :

ហេង សំរិន

ក្រឹត្យលេខ ៧១ ក្រ

ក្រុមប្រឹក្សារដ្ឋ

នៃរដ្ឋកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្ដីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ១៩៨២

សំរេច

ប្រកាសអោយប្រើច្បាប់ ស្ដីពីការលុបចោលសន្ធិសញ្ញាមិត្តភាព និង សហប្រតិបត្តិការរវាង សាធារណរដ្ឋប្រជាមានិតកម្ពុជា និង សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ និង អនុសញ្ញាកុងស៊ុល រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

ក្រឹត្យលេខ ៧២ ក្រ

ក្រុមប្រឹក្សារដ្ឋ

នៃរដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

- បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

- បានឃើញសេចក្តីសំរេចរបស់រដ្ឋសភា លេខ ០៧.៩០រស លេខ ០៨.៩០រស លេខ០៩.៩០រស ១០.៩០រស និងលេខ ១១.៩០ រស ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

សំរេច

មាត្រា ១ .- ត្រូវបាន :

១- សំរួលភារកិច្ចសមមិត្ត ហ៊ុន សែន ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស ដោយអោយឈប់ទទួលជារដ្ឋមន្ត្រីក្រសួងការបរទេស ។

២- សំរួលភារកិច្ចសមមិត្ត សាយ ឈុំ អនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងកសិកម្ម ដោយអោយឈប់ទទួលរដ្ឋមន្ត្រីក្រសួងកសិកម្ម ។

៣- ដំរោយសមមិត្ត តាំង សារីម ពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយត្រូវចូលនិវត្តន៍ ។

៤- តែងតាំងសមមិត្ត ឌួន ញ៉ុល ជារដ្ឋមន្ត្រីក្រសួងកសិកម្ម ។

៥- តែងតាំងសមមិត្ត ញឹម វណ្ណដា ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

៦- តែងតាំងសមមិត្ត ហោ ណាំហុង ជារដ្ឋមន្ត្រីក្រសួងការបរទេស ។

មាត្រា២ :- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

ក្រឹត្យលេខ ៧៥ ក្រ

ក្រុមប្រឹក្សារដ្ឋ

នៃ រដ្ឋកម្ពុជា

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

សំរេច

មាត្រា ១ — ត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ជំនួយការសមមិត្តប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី :

១— សមមិត្ត ស៊ុខ គឹមអន បច្ចុប្បន្ន ប្រធាននាយកដ្ឋានសរុប នៃក្រសួងការបរទេស

២— ទេព ហែន បច្ចុប្បន្ន ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃ រដ្ឋកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម

មាត្រា ២ — ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

ក្រឹត្យ លេខ ៧៦ ក្រ

ក្រុមប្រឹក្សារដ្ឋ

នៃ រដ្ឋកម្ពុជា

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

សំរេច

មាត្រា ១ — ត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រី ក្រសួងការបរទេស :

១— សមមិត្ត សោក សេដ្ឋា   បច្ចុប្បន្នប្រធានមន្ទីរក្រសួងការបរទេស

២— សមមិត្ត តី ចាន   បច្ចុប្បន្នប្រធាននាយកដ្ឋាន សូវៀត អឺរ៉ុបខាងកើត នៃ ក្រសួងការបរទេស

មាត្រា ២ — ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

III- ក្រុមប្រឹក្សារដ្ឋមន្ត្រី

១ — អនុក្រឹត្យ

ភ្នំពេញ , ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

អនុក្រឹត្យលេខ ២៨ អនក្រ

ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានចំការកៅស៊ូ

ក្រុមប្រឹក្សារដ្ឋមន្ត្រី

បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ . ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ស្តីពីការកែប្រែការចាត់តាំងតួនាទី និង ភារកិច្ចរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ១២ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ១៩៩០

— បានឃើញ ក្រឹត្យ - ច្បាប់ លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ញា

— តាមសំណើរបស់រដ្ឋមន្ត្រីទទួលផ្ទាល់អគ្គនាយកដ្ឋានចំការកៅស៊ូ

សំរេច

មាត្រា ១ .- អគ្គនាយកដ្ឋានចំការកៅស៊ូ ជាស្ថាប័នស្ថិតក្រោមឱវាទក្រុមប្រឹក្សារដ្ឋមន្ត្រី មានតួនាទីគ្រប់គ្រង និង ធ្វើអាជីវកម្មកៅស៊ូទូទាំងប្រទេស ។

មាត្រា ២ .— អគ្គនាយកដ្ឋានចំការកៅស៊ូ មានភារកិច្ច និង សិទ្ធិដូចខាងក្រោម :

— គ្រប់គ្រងការដាំដុះ ការធ្វើអាជីវកម្មកៅស៊ូ ការផ្គត់ផ្គង់សម្ភារៈ បរិក្ខារបំរើអោយវិស័យកៅស៊ូរបស់រដ្ឋ ។

— ស្រាវជ្រាវ និង សហការជាមួយស្ថាប័ន ក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំដាក់ជូនក្រុមប្រឹក្សារដ្ឋមន្ត្រីសំរេច ហើយផ្សព្វផ្សាយ ណែនាំអនុវត្តអំពីគោលការណ៍គោលនយោបាយផែនការបង្កើនបច្ចេកទេសសេដ្ឋកិច្ច ពលកម្ម របបស្វ័យភាពហិរញ្ញវត្ថុ ហិរញ្ញកិច្ចរបស់ក្រុមហ៊ុនអាជីវកម្មសម្ភារៈបរិក្ខារក្នុងវិស័យកៅស៊ូ ការអភិវឌ្ឍន៍វិទ្យាសាស្ត្របច្ចេកទេស ការដាំដុះ ការធ្វើអាជីវកម្ម

ការនាំចេញកៅស៊ូ ការនាំចូលសម្ភារៈបរិក្ខារ ឧបករណ៍ វត្ថុធាតុដើម ជាតិគីមី បំរើអោយវិស័យកៅស៊ូ និង ធ្វើសេចក្តីព្រាងច្បាប់ ស្តីពីការការពារ និង ការគ្រប់គ្រងភោគផលដំណាំកៅស៊ូជូនថ្នាក់លើពិនិត្យ និង សំរេច ។

– រៀបចំស្រាវជ្រាវ ចងក្រង និង បណ្តុះបណ្តាលកម្មាភិបាល បុគ្គលិក កម្មករ និស្សិតមុខជំនាញវិទ្យាសាស្ត្របច្ចេកទេសក្នុងវិស័យកៅស៊ូ ។

– ធ្វើនិហរណកម្មកៅស៊ូ និង អាហរណកម្ម នូវសម្ភារៈបរិក្ខារបំរើវិស័យកៅស៊ូ ។

– តាមដានត្រួតពិនិត្យការធ្វើអាជីវកម្មកៅស៊ូ និងការផ្គត់ផ្គង់សម្ភារៈបរិក្ខារបំរើវិស័យកៅស៊ូ ។

មាត្រា ៣ .– រចនាសម្ព័ន្ធចាត់តាំងរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ រួមមាន :

១ – មន្ទីរ

២ – នាយកដ្ឋានចាត់តាំង និង បៀវត្សរ៍ពលកម្ម

៣ – នាយកដ្ឋានផែនការហិរញ្ញវត្ថុ និង សហប្រតិបត្តិការ

៤ – នាយកដ្ឋានបច្ចេកទេស

៥ – គណៈកម្មាធិការត្រួតពិនិត្យ ថ្នាក់ស្មើនាយកដ្ឋាន

៦ – វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិ ថ្នាក់ស្មើនាយកដ្ឋាន

៧ – ក្រុមហ៊ុនចំការកៅស៊ូ ៧ មករា ថ្នាក់ស្មើនាយកដ្ឋាន

៨ ក្រុមហ៊ុនចំការកៅស៊ូមិត្តភាព ថ្នាក់ស្មើនាយកដ្ឋាន

៩ – ក្រុមហ៊ុនចំការកៅស៊ូសាមគ្គី ថ្នាក់ស្មើនាយកដ្ឋាន

១០ – ក្រុមហ៊ុនដឹកជញ្ជូនអាហរណ៍ និហរណ៍ និង សម្ភារៈបរិក្ខារកៅស៊ូ ថ្នាក់ស្មើនាយកដ្ឋាន

១១ – ក្រុមហ៊ុនចំការកៅស៊ូក្រែក ថ្នាក់ស្មើនាយកដ្ឋាន

១២ – ក្រុមហ៊ុនចំការកៅស៊ូបឹងកេត ថ្នាក់ស្មើនាយកដ្ឋាន

១៣ – ក្រុមហ៊ុនចំការកៅស៊ូ ២ ធ្នូ ថ្នាក់ស្មើនាយកដ្ឋាន

១៤ – មន្ទីរសុខាភិបាលចំការកៅស៊ូ និង ក្រុមហ៊ុនចំរើនភាពចំការកៅស៊ូ ថ្នាក់ស្មើមន្ទីរនានាចំណុះគណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ។

មន្ទីរ នាយកដ្ឋាន វិទ្យាស្ថានស្រាវជ្រាវ ក្រុមហ៊ុន គណៈកម្មាធិការត្រួតពិនិត្យ មន្ទីរសុខាភិបាល មានប្រធានមួយរូប និង អនុប្រធានជំនួយការ ។

ភារកិច្ចជាក់ស្តែង ការរៀបចំក្រមខ័ណ្ឌ របៀបរបប និង បទបញ្ជាធ្វើការងាររបស់អង្គភាពនានាខាងលើ អាស្រ័យដោយអគ្គនាយកដ្ឋានចំការកៅស៊ូកំណត់ ។

មាត្រា ៤ .— បទបញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ .— ទីស្តីការគណៈរដ្ឋមន្ត្រី អគ្គនាយកដ្ឋានចំការកៅស៊ូ ក្រសួង ស្ថាប័នពាក់ព័ន្ធ និង គណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា ៦ អនុក្រឹត្យនេះ មានអនុភាពគតិយុត្តិចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

ភ្នំពេញ , ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

អនុក្រឹត្យលេខ ២៩ អនក្រ

ស្តីពី សត្តឃាតដ្ឋាន និង កន្លែងពិឃាតសត្វ

ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញសេចក្តីសំរេចកំណត់លេខ ៨៥.៨០ គប ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៨០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ស្តីអំពីតួនាទីភារកិច្ច និង អង្គការចាត់តាំងក្បាលម៉ាស៊ីនរបស់ក្រសួងកសិកម្ម

— បានឃើញក្រឹត្យច្បាប់ លេខ ០៧ ក្រច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា

— តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម

សំរេច

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១. — អនុញ្ញាតអោយបង្កើតសត្តឃាតដ្ឋាន ឬ កន្លែងពិឃាតសត្វ ដើម្បីធានាសុខភាពសាធារណៈ ។

មាត្រា ២. — អាចបង្កើតអោយមានកន្លែងពិឃាតសត្វមួយសម្រាប់ស្រុក ខ័ណ្ឌនិមួយ ។ និងសត្តឃាតដ្ឋាន ឬកន្លែងពិឃាតសត្វមួយសម្រាប់ទីរួមខេត្ត ឬ ទីក្រុងនិមួយ ។ ក្នុងករណីចាំបាច់អាចបង្កើត ឬអនុញ្ញាតអោយបង្កើតសត្តឃាតដ្ឋាន ឬកន្លែងពិឃាតសត្វថែមទៀតបាន នៅក្នុងទីប្រជុំជនធំ ។ យោលទៅតាមស្ថានភាពភូមិសាស្ត្រ និងចំនួនប្រជាជននៅមូលដ្ឋាននោះ ។

មាត្រា ៣. — សត្តឃាតដ្ឋាន ឬ កន្លែងពិឃាតសត្វ ត្រូវមានទីតាំងនៅកន្លែងសមស្រប ធានាអនាម័យ និងលក្ខខ័ណ្ឌបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការពិឃាតសត្វ ពិនិត្យសាច់ និងអនុវត្តវិធានការបសុពេទ្យដែលនឹងកំណត់ដោយក្រសួងកសិកម្ម ។

មាត្រា ៤. — ការធ្វើអាជីវកម្មពិឃាតសត្វយកសាច់ ត្រូវធ្វើនៅកន្លែងពិឃាតសត្វ ឬ នៅសត្តឃាតដ្ឋាន ។

មាត្រា ៥. — ការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន និងអនាម័យ កន្លែងពិឃាតសត្វ អនាម័យសត្តឃាត អនាម័យសត្វ និង សាច់ ជាសមត្ថកិច្ចរបស់អង្គភាពផលិត-កម្ម និង បសុព្យាបាល ។

ជំពូកទី ២

ការបង្កើតសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និង ការធ្វើអាជីវកម្មពិឃាតសត្វ

មាត្រា ៦. — ការបង្កើតសត្តឃាតសត្វ និង កន្លែងពិឃាតសត្វ និងការអនុញ្ញាតអោយធ្វើអាជីវកម្មពិឃាតសត្វនៅក្នុងទីរួមខេត្ត-ក្រុង. ត្រូវសំរេចដោយគណៈកម្មា-ធិការប្រជាជនខេត្ត- ក្រុង តាមសំណើរបស់ការិយាល័យផលិតកម្ម និង បសុព្យាបាលនៃខេត្ត-ក្រុងនោះ ។

ការបង្កើតសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និង ការអនុញ្ញាតអោយធ្វើអាជីវកម្មពិឃាតសត្វ

នៅក្នុងស្រុក- ខ័ណ្ឌ និង មីប្រជុំជន - ត្រូវសំរេចដោយគណៈកម្មាធិការប្រជាជនស្រុក ខ័ណ្ឌ តាមសំណើរបស់ផ្នែកផលិតកម្ម និង បសុព្យាបាលនៃស្រុក- ខ័ណ្ឌនោះ ។

មាត្រា ៧ .— អាជីវករដែលបានទទួលការអនុញ្ញាត អោយធ្វើអាជីវកម្មពិឃាតសត្វយកសាច់មានការព្វកិច្ចដូចតទៅ :

១ .- ប្រមូលផ្តុំសត្វដែលជាកម្មវត្ថុ នៃ ការពិឃាតនៅសត្តឃាតដ្ឋាន ឬ នៅកន្លែងពិឃាតសត្វដែលបានកំណត់ដើម្បីពិឃាតយកសាច់ ។

២ — ត្រូវដឹកជញ្ជូនដល់សត្តឃាតដ្ឋាន ឬកន្លែងពិឃាតសត្វអោយបាន ២៤ ម៉ោងយ៉ាងតិច ឬ ៤៨ ម៉ោងយ៉ាងច្រើនមុននឹងសំលាប់យកសាច់ លើកលែងតែសត្វរបស់គ្រួសារប្រជាជនដែលនៅជិត ៗ នោះ ឬក្នុងករណីសត្វត្រូវពិឃាតជាបន្ទាន់ ហើយត្រូវមានលិខិតបញ្ជាក់អនាម័យចេញដោយភ្នាក់ងារបសុពេទ្យប្រចាំមូលដ្ឋានបញ្ជាក់ថា :

« សត្វមានសុខភាពល្អដឹកជញ្ជូនចេញពីតំបន់គ្មានកើតជម្ងឺឆ្លង »

៣ - ដឹកជញ្ជូនសាច់ចេញពីសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វតាមវិធានទ និង បទបញ្ជាបសុពេទ្យ ។

មាត្រា ៨ .— ហាមមិនអោយពិឃាតសត្វយកសាច់ក្រៅពីសត្តឃាតដ្ឋាន ឬកន្លែងពិឃាតសត្វ ។

ក្នុងករណីចាំបាច់គណៈកម្មាធិការប្រជាជនឃុំ. សង្កាត់ អាចអនុញ្ញាតអោយប្រជាជនពិឃាតនៅមូលដ្ឋានរបស់ខ្លួន ដើម្បីយកសាច់ប្រើប្រាស់ផ្ទាល់ក្នុងពិធីបុណ្យផ្សេង ៗ តែត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារបសុពេទ្យ ។

ហាមមិនអោយពិឃាតសត្វឈឺ ឬ រះសត្វស្លាប់ដោយជម្ងឺឆ្លង ដើម្បីយកសាច់បរិភោគ ឬលក់ ក្នុងករណីត្រូវពិឃាត ឬ ត្រូវរះសត្វនោះដើម្បីធ្វើការពិសោធន៍ស្រាវជ្រាវត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារបសុពេទ្យ ។

ជំពូកទី ៣

សមត្ថកិច្ចរបស់អង្គភាពផលិតកម្ម និង បសុព្យាបាល

មាត្រា ៩ .— ផ្នែកផលិតកម្ម និង បសុព្យាបាលស្រុក- ខ័ណ្ឌ មានសមត្ថកិច្ចត្រួតពិនិត្យអនាម័យ កន្លែងពិឃាតសត្វ អនាម័យសត្តឃាត អនាម័យសត្វ និង អនាម័យសាច់ នៅថ្នាក់ស្រុក- ខ័ណ្ឌ និង មីប្រជុំជន ។

ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត-ក្រុង មានសមត្ថកិច្ចត្រួតពិនិត្យអនាម័យនៃសត្តឃាតដ្ឋាន និង កន្លែងពិឃាតសត្វ អនាម័យនៃការពិឃាតសត្វ អនាម័យសត្វ និងអនាម័យសាច់នៅទីរួមខេត្ត-ក្រុង ព្រមទាំងមានសមត្ថកិច្ចចុះត្រួតពិនិត្យការងាររបស់ផ្នែកផលិតកម្ម និងបសុព្យាបាលថ្នាក់ស្រុក ខ័ណ្ឌ និង ទីប្រជុំជន ។

នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានសមត្ថកិច្ចណែនាំបច្ចេកទេស និងត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ អនាម័យនៃការពិឃាតសត្វ អនាម័យសត្វ និងអនាម័យសាច់នៅលើទឹកដីនៃរដ្ឋកម្ពុជា ។

មាត្រា ១០ . – ក្នុងពេលបំពេញភារកិច្ចភ្នាក់ងារបសុពេទ្យប្រចាំសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វមានភារកិច្ច និងសិទ្ធិដូចតទៅ ៖

– ពិនិត្យសត្វរស់មុនពិឃាត ពិនិត្យសាច់សត្វពិឃាតហើយ និងកំណត់គុណភាពសាច់

– អនុញ្ញាត ឬមិនអនុញ្ញាតអោយពិឃាតសត្វ ឬប្រើប្រាស់សាច់សត្វពិឃាតហើយ

– ចេញលិខិតបញ្ជាក់អនាម័យ បោះត្រាលើសត្វរស់ និងលើសាច់

– ចាត់វិធានការបសុពេទ្យលើសត្វ និងសាច់ដែលឈឺ ឬខ្វះអនាម័យ

កត់ត្រា និងបញ្ជាក់លើសៀវភៅពិឃាតសត្វ

ធ្វើកំណត់ហេតុក្នុងករណីមានបទល្មើស

មាត្រា ១១ . – អង្គភាពផលិតកម្ម និងបសុព្យាបាល មានសិទ្ធិដូចតទៅ ៖

ក – ផ្នែកផលិតកម្ម និងបសុព្យាបាលស្រុក ខ័ណ្ឌ មានសិទ្ធិ :

– ព្រមាន

– ពិន័យជាប្រាក់ចំពោះបទល្មើសដែលកើតឡើងក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន

– ឃាត់ទុកជាបណ្តោះអាសន្ន នូវ សាច់ សត្វ ដើម្បីធ្វើការត្រួតពិនិត្យអនាម័យ

– ឃាត់ទុកជាបណ្តោះអាសន្ន នូវ វត្ថុតាង បង្ហូរមិនអោយប្រើប្រាស់សត្វ សាច់ដែលខ្វះគុណភាព ឬខ្វះអនាម័យ ។

– បញ្ឈប់ជាបណ្តោះអាសន្ន នូវ ការធ្វើអាជីវកម្មពិឃាតសត្វយកសាច់

ក្នុងករណីដែលត្រូវបញ្ឈប់ការធ្វើអាជីវកម្មពិឃាតសត្វយកសាច់ជាស្ថាពរ ផ្នែកផលិតកម្ម និងបសុព្យាបាល ត្រូវស្នើសុំសេចក្តីសំរេចពីប្រធានគណៈកម្មាធិការប្រជាជននៃស្រុក ខ័ណ្ឌ នោះ ។

ខ – ការិយាល័យផលិតកម្ម និងបសុព្យាបាលមានសិទ្ធិ :

— ព្រមាន

— ពិន័យជាប្រាក់ចំពោះបទល្មើសដែលកើតឡើងក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន

ឃាត់ទុកជាបណ្ដោះអាសន្ន នូវ សត្វ សាច់ ដើម្បីធ្វើការត្រួតពិនិត្យអនាម័យ

- ឃាត់ទុកជាបណ្ដោះអាសន្ននូវវត្ថុតាង

— បង្វែរទិសប្រើប្រាស់សត្វ សាច់ដែលខ្វះគុណភាព ឬខ្វះអនាម័យ

— បញ្ឈប់ជាបណ្ដោះអាសន្ននូវការធ្វើអាជីវកម្មពិឃាតសត្វយកសាច់

ក្នុងករណីដែលត្រូវបញ្ឈប់ការធ្វើអាជីវកម្មពិឃាតសត្វយកសាច់ជាស្ថាពរ ការិយាល័យផលិតកម្ម និង បសុព្យាបាល ត្រូវស្នើសុំសេចក្ដីសម្រេចពីគណៈកម្មាធិការប្រជាជននៃខេត្ត ក្រុង នោះ ។

គ– នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលមានសិទ្ធិ :

— ព្រមាន

— ពិន័យជាប្រាក់ចំពោះបទល្មើសដែលកើតឡើងក្នុងទូទាំងប្រទេស

— ឃាត់ទុកជាបណ្ដោះអាសន្ន នូវ សត្វ សាច់ ដើម្បីធ្វើការត្រួតពិនិត្យអនាម័យ

— ឃាត់ទុកជាបណ្ដោះអាសន្ននូវវត្ថុតាង

– បង្វែរទិសប្រើប្រាស់សត្វ សាច់ ដែលខ្វះគុណភាព ឬខ្វះអនាម័យ

មាត្រា ១២ .– សមត្ថកិច្ចដោះស្រាយបណ្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់អង្គភាពផលិតកម្ម និងបសុព្យាបាល ត្រូវកំណត់ដូចខាងក្រោម :

— ការតវ៉ានឹងសេចក្ដីសម្រេចរបស់ផ្នែកផលិតកម្ម និងបសុព្យាបាលត្រូវការិយាល័យផលិត-កម្ម និងបសុព្យាបាលខេត្ត-ក្រុង ជាអ្នកពិនិត្យនិងសម្រេច ។

ការតវ៉ានឹងសេចក្ដីសម្រេចរបស់ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត-ក្រុងត្រូវនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលជាអ្នកពិនិត្យនិងសម្រេច ។

ប្រសិនបើមានការតវ៉ានឹងសេចក្ដីសម្រេចរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនោះ ត្រូវរដ្ឋមន្ត្រីក្រសួងកសិកម្មជាអ្នកពិនិត្យនិងសម្រេច ។ សេចក្ដីសម្រេចរបស់ក្រសួងកសិកម្មជាសេចក្ដីសម្រេចចុងក្រោយ ។

ក្នុងករណីដែលជនល្មើសមិនព្រមបង់ប្រាក់ពិន័យ ឬត្រូវរឹបអូសវត្ថុតាងនោះត្រូវបញ្ជូនទៅតុលាការប្រជាជនសម្រេច ។

ប្រសិនបើសាច់ដែលឃាត់ពីការប្រព្រឹត្តបទល្មើសហើយទុកយូរមិនបាន ភ្នាក់ងារបសុព្យាបាល

អាចលក់បានដោយគ្មានកំណត់ពេល ប៉ុន្តែត្រូវធ្វើកំណត់ហេតុបញ្ជូនទៅតុលាការដើម្បីអោយសច្ចាប័ន ។

ប្រាក់ពិន័យត្រូវបង់ចូលថវិការដ្ឋ ។

មាត្រា ១៣ .- ក្នុងពេលបំពេញភារកិច្ចភ្នាក់ងារបសុពេទ្យប្រចាំសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ ត្រូវស្លៀកពាក់តាមការកំណត់របស់ក្រសួងកសិកម្ម ។

មាត្រា ១៤ .- រដ្ឋអំណាចមូលដ្ឋាននានា កងកម្លាំងប្រដាប់អាវុធ ត្រូវជួយផ្ដល់កម្លាំងក្នុងការរក្សាសណ្ដាប់ធ្នាប់សត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងក្នុងការត្រួតពិនិត្យបទល្មើស ក្នុងករណីដែលខាងការស្នើសុំពីអង្គភាពផលិតកម្ម និងបសុព្យាបាល ។

ជំពូកទី ៤

ទោសបញ្ញត្តិ

មាត្រា ១៥ .- ជនណាប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ ត្រូវព្រមាន ពិន័យជាប្រាក់ រឹបអូសវត្ថុតាងបង្វែរមិនសប្រើប្រាស់ ឬសាច់ បញ្ឈប់ជាបណ្ដោះអាសន្ន ឬជាស្ថាពរនូវការធ្វើអាជីវកម្ម ពិឃាតសត្វយកសាច់ ។

មាត្រា ១៦ .- អាជីវកម្មដែលមិនអនុវត្តតាមខទបញ្ញត្តិនៃមាត្រា ៧ នៃអនុក្រឹត្យនេះត្រូវព្រមាន ។

ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់រហូតដល់មួយភាគដប់នៃតំលៃសត្វ ឬសាច់ ឬបញ្ឈប់អាជីវកម្មពិឃាតសត្វជាបណ្ដោះអាសន្នក្នុងរយៈពេលពី ១ ខែ ទៅ ៣ ខែ ឬ បញ្ឈប់ការធ្វើអាជីវកម្មពិឃាតសត្វជាស្ថាពរ ។

មាត្រា ១៧ .- ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៨ វាក្យខណ្ឌទី ១ និងទី ២ នៃអនុក្រឹត្យនេះត្រូវព្រមាន ។

ក្នុងករណីដែលបទល្មើសមានលក្ខណៈធ្ងន់ធ្ងរ ត្រូវពិន័យជាប្រាក់ស្មើនឹងមួយភាគបីនៃតំលៃសត្វ ឬ សាច់ ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ស្មើនឹងពាក់កណ្ដាលតំលៃសត្វ ឬសាច់ រីឯវត្ថុតាងត្រូវរឹបអូស ។

មាត្រា ១៨ .- ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៨ វាក្យខណ្ឌទី ៣ នៃអនុក្រឹត្យនេះ ត្រូវពិន័យជាប្រាក់ស្មើនឹងតំលៃសាច់ ឬសាច់ដែលគ្មានជំងឺ នឹងបង្វែរមិនសប្រើប្រាស់សាច់ ឬសត្វទាំងនោះ ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេមួយជាពីរនៃតំលៃសាច់ ឬ សត្វដែលគ្មានជំងឺ និងចង្អៀតទិសប្រើប្រាស់សត្វទាំងនោះ ។ ប្រសិនបើអំពើល្មើសនោះបង្កអោយមានការអន្តរាយដល់សុខភាពសាធារណៈ នោះត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន

មាត្រា ១៩ .— ជនណាធ្វើអាជីវកម្មពិឃាតសត្វយកសាច់ដោយគ្មានច្បាប់អនុញ្ញាត ត្រូវពិន័យជាប្រាក់ហាសិបភាគរយនៃតម្លៃសត្វ ឬ សាច់ ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ស្មើនឹងតម្លៃសត្វ ឬ សាច់ ។ រីឯវត្ថុតាងត្រូវរឹបអូស ។

មាត្រា ២០ .— ជនណាលាក់បិទបាំងអំពើល្មើស តែបំបាត់ប្រាក់ពិន័យ ឬ វត្ថុតាង ប្រព្រឹត្តិខុសក្រម ប្រព្រឹត្តល្មើសក្នុងបទសំណូក ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ជំពូកទី ៥

បទបញ្ញត្តិជាអវសាន

មាត្រា ២១ : — បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២២ .— រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រដ្ឋមន្ត្រីក្រសួងពាណិជ្ជ និង គណៈកម្មាធិការប្រជាជនខេត្ត- ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា ២៣ .— អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃដែលប្រកាសផ្សាយជាសាធារណៈ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ខា សុខ

២- សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ១៩៩០

សេចក្តីសំរេច លេខ ១៥៦ សសរ

ស្តីពីថ្លៃលក់ថាមពលអគ្គិសនី និងទឹក

ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

- បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសាកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលបេ-ប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៨២

- យោងស្មារតីអង្គប្រជុំគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩០

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

សំរេច

ប្រការ ១ : កំណត់ថ្លៃលក់ថាមពលអគ្គិសនី និងទឹក ដូចខាងក្រោម ៖

- អគ្គិសនី : ៣៣,០០ ក្នុង ១ គវម
- ទឹក : ៣៦,០០ ក្នុង ១ ម^{៣}

ប្រការ ២ : ផ្អែកតាមកំរិតថ្លៃក្នុងប្រការ ១ នៃសេចក្តីសំរេចនេះ គណៈកម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ មានភារកិច្ចណែនាំការអនុវត្តជាក់ស្តែង ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណាដែលមានពីមុន ហើយមានន័យផ្ទុយពីសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ និងគណៈ-កម្មាធិការប្រជាជនរដ្ឋធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ។

សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩១ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ចា ស៊ុម

ភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

សេចក្តីសំរេច លេខ ១៥៧ សសរ

ស្តីពីថ្លៃទិញឈើមូល ឆ្នាំ ១៩៩០ – ១៩៩១

ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– យោងស្មារតីអង្គប្រជុំគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩០

– តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងផែនការ

សំរេច

ប្រការ ១ : កំណត់ថ្លៃទិញឈើមូលលេខ ២ នៅតំបន់ទី ១ របស់ក្រុមសាមគ្គី និងអង្គភាពអាជីវកម្មព្រៃឈើ ៤.៥០០៛ "បួនពាន់ប្រាំរយរៀល" ក្នុងមួយម៉ែត្រគីប ។

ប្រការ ២: ផ្អែកតាមកំរិតថ្លៃក្នុងប្រការ ១ ខាងលើ ក្រសួងផែនការមានភារកិច្ចកំណត់ថ្លៃទិញតាមប្រភេទ និងគុណភាពឈើនីមួយៗ កំណត់ថ្លៃលក់ដុំឧស្សាហកម្មឈើមូលគ្រប់ប្រភេទនៅតំបន់ទី១ តំបន់ទី ២ និងថ្លៃលក់ដុំឧស្សាហកម្មឈើអារ ហើយនិងណែនាំការអនុវត្តជាក់ស្តែង ។

ប្រការ ៣ : ក្រសួងកសិកម្ម និងខេត្ត-ក្រុង ដែលមានភារកិច្ចផ្គត់ផ្គង់ឈើជូនរដ្ឋ ត្រូវយកចិត្តទុកដាក់កំរិតខ្ពស់ ក្នុងការបំពេញកំរិតកំណត់ផែនការរដ្ឋ ។

ប្រការ ៤ : ចំណុចបញ្ញត្តិទាំងឡាយណាដែលមានពីមុន ហើយមានន័យផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ ក្រសួងកសិកម្ម ក្រសួងពាណិជ្ជកម្ម ធនាគារជាតិកម្ពុជា និងគណៈកម្មាធិការខេត្ត-ក្រុង មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ។

– សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ

ភ្នំពេញ , ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

សេចក្តីសំរេចលេខ ១៥៨ សសរ
ស្តីពីឋានានុក្រមគ្រប់គ្រងថ្លៃ
ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី , ដែលប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— យោងស្មារតីអង្គប្រជុំគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ១៩៩០

– តាមសំណើរដ្ឋមន្ត្រី ក្រសួងផែនការ ។

សំរេច

ប្រការ ១ : កំណត់ឋានានុក្រមគ្រប់គ្រងថ្លៃ ដូចមានខ្លឹមសារក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសំរេចនេះ

ប្រការ ២ : ក្រសួងផែនការ មានភារកិច្ចទទួលខុសត្រូវ ណែនាំការអនុវត្តន៍ជាក់ស្តែង និងតាមដានត្រួតពិនិត្យលើគ្រប់បណ្តាផ្នែក បណ្តាថ្នាក់ បណ្តាមូលដ្ឋានផលិតកម្ម–អាជីវកម្មអោយប្រតិបត្តិត្រឹមត្រូវតាមគោលនយោបាយថ្លៃ គោលការណ៍ វិធីសាស្ត្រគសាងថ្លៃ របបគ្រប់គ្រងថ្លៃ និងថ្លៃណែនាំរបស់រដ្ឋ ។ ក្នុងករណីចាំបាច់ត្រូវមានការកែសំរួល ឬបំពេញបន្ថែមទៀតក្រសួងផែនការមានភារកិច្ចពិនិត្យសំណូមពររួម ដើម្បីផ្តល់មតិជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ពិចារណា និងសំរេច ។

ប្រការ ៣ : បណ្តាក្រសួង គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវណែនាំដល់បណ្តាស្ថាប័ន សហគ្រាសក្រោមឱវាទ អោយអនុវត្តត្រឹមត្រូវរាល់គោលនយោបាយថ្លៃ គោលការណ៍ វិធីសាស្ត្រកសាងថ្លៃ របបគ្រប់គ្រងថ្លៃ និងថ្លៃណែនាំរបស់រដ្ឋ ។

ប្រការ ៤ : បណ្តាក្រសួង និងអង្គភាពផលិតកម្ម – អាជីវកម្ម សេវាកម្ម ស្វ័យាភិបាលសេដ្ឋកិច្ច ត្រូវផ្ញើរាល់សេចក្តីសំរេចថ្លៃរបស់ខ្លួន មកក្រសួងផែនការអោយបានទៀងទាត់ ។

ប្រការ ៥ : សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ១៣៤ សសរ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ស្តីពីបាទានុក្រមគ្រប់គ្រងថ្លៃ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី បណ្តាក្រសួង ស្ថាប័នទៅមជ្ឈឹម និងគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត - ក្រុង មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយបានប្រសិទ្ធភាពខ្ពស់ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

ឧបសម្ព័ន្ធបាទានុក្រមគ្រប់គ្រងថ្លៃ (ភ្ជាប់សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៥៨ សសរ ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩០)

ខ្លឹមសារគ្រប់គ្រងរដ្ឋលើការងារថ្លៃ

១ – សេចក្តីផ្តើម :

ក្រោយពេលលើកឡើងលាយការអនុវត្តន៍ថ្លៃស្រុះស្រួល ថ្លៃធានាអាជីវកម្ម លើមូលដ្ឋានថ្លៃទីផ្សារ តាមគោលនយោបាយសេដ្ឋកិច្ចថ្មី រដ្ឋបានបន្ថយមួយកំរិត នូវតួនាទីកំណត់ថ្លៃ ដែលបានធ្វើអោយកើតមានឡើងនូវស្ថានភាពការណ៍ថ្មីក្នុងការងារថ្លៃ ។ ការខ្វះខាតក្នុងការគ្រប់គ្រងរបស់រដ្ឋ លើការកសាង និងអនុវត្តថ្លៃ បណ្តាលមកពីយើងអនុវត្ត ពុំបានច្បាស់លាស់ពីតួនាទី ភារកិច្ចរបស់ខ្លួន នៅក្នុងគោលនយោបាយថ្មី ។ បណ្តាក្រឹត្យច្បាប់សេដ្ឋកិច្ច ជាលាយលក្ខណ៍អក្សរ ដែលជាមូលដ្ឋាននៃការចាត់តាំងសកម្មភាពខ្សែរយៈថ្លៃ នៅខ្វះខ្លឹមសារសំខាន់ៗ ជាច្រើនអោយសមស្របទៅនឹងគោលនយោបាយថ្មី នៃការគ្រប់គ្រងសេដ្ឋកិច្ចទំនិញ ដែលមានច្រើនសមាសភាពសេដ្ឋកិច្ចនៅក្នុងដំណាក់កាលបច្ចុប្បន្ន ។ ម្យ៉ាងវិញទៀត រដ្ឋពុំមានលទ្ធភាពរក្សាថ្លៃអោយបានស្ថេរភាព និងពុំទាន់អាចធ្វើការព្យាករណ៍ចំពោះស្ថានភាពការណ៍ សេដ្ឋកិច្ចនាពេលខាងមុខ ដើម្បីគ្រប់គ្រងសេដ្ឋកិច្ចតាមបែបទ្រង់ទ្រាយធំ ។

២ – ខ្លឹមសារគ្រប់គ្រងរដ្ឋលើការងារថ្លៃ ៖

ខ្លឹមសារនៃការគ្រប់គ្រងរបស់រដ្ឋ លើការងារថ្លៃក្នុងរចនាសម្ព័ន្ធគ្រប់គ្រងខឿនសេដ្ឋកិច្ចទំនិញមានផែនការ ដែលមានច្រើន សមាសភាពសេដ្ឋកិច្ច ត្រូវបានផ្លាស់ប្តូរជាមូលដ្ឋានដូចតទៅ ៖

ក – បន្ថយសិទ្ធិកំណត់ថ្លៃទំនិញ និង ថ្លៃលក់បណ្តាផលិតផលជាក់ស្តែង ៖

រដ្ឋប្រគល់សិទ្ធិម្ចាស់ការសំរុះសំរួលថ្លៃជូនបណ្តាអ្នកផលិត អ្នកធ្វើជំនួញ និងអ្នកប្រើប្រាស់ ។ រដ្ឋកំណត់តែ ថ្លៃសម្ភារៈឧបករណ៍មួយចំនួនតូច វត្ថុធាតុដើមទាំងឡាយសំខាន់ចាំបាច់ចំពោះផលិតកម្ម ផលិតផលកសិកម្មជាយុទ្ធសាស្ត្រមួយចំនួន ។ ក្នុងករណីចាំបាច់រដ្ឋសំរេចការឧបត្ថម្ភថ្លៃមានរយៈពេលដើម្បីការពារផលិតកម្ម និងបំរើវិស័យការពារប្រទេសចំពោះទំនិញដែលសំខាន់ចាំបាច់បំផុតចំពោះខឿនសេដ្ឋកិច្ចជាតិ ដែលសហគ្រាសពុំទាន់ម្ចាស់ការលើមុខចំណាយ ។

ជាជំហាន ៗ ទៅតាមដំណាក់កាលរីកចំរើននៃខឿនសេដ្ឋកិច្ចជាតិ រដ្ឋនឹងបន្ថយការអន្តរាគមន៍ដោយផ្ទាល់ចំពោះ ថ្លៃទំនិញ និងថ្លៃលក់ផលិតផលជាក់ស្តែង ។

ខ – បង្កើនការគ្រប់គ្រងទ្រង់ទ្រាយធំ អនុវត្តតួនាទីត្រួតពិនិត្យរបស់រដ្ឋ ចំពោះថ្លៃដែលកើតឡើងតាមរចនាសម្ព័ន្ធស្រុះស្រួល ដោះបញ្ហាទំនាក់ទំនងការផ្គត់ផ្គង់ និងសេចក្តីត្រូវការ ឆ្លងតាមការប្រណាំងប្រជែងនឹងគ្នា ។ ជំរុញខ្លាំងសកម្មភាព និងបង្កើនគុណភាពពិតមានថ្លៃច្រើន ធ្វើអោយបានល្អ ការងារចាត់តាំងអនុវត្តថ្លៃស្រុះស្រួល ។

គ – ប្រើប្រាស់បណ្តាវិធានការសរុប កំលាំងសរុបដើម្បីគ្រប់គ្រងតាមបែបទ្រង់ទ្រាយធំ សំដៅជះឥទ្ធិពលទៅលើទំនាក់ទំនងការផ្គត់ផ្គង់ និងតំរូវការរបស់ទីផ្សារ ដើម្បីកំណត់ទិសដៅនៃសកម្មភាព ផលិតកម្ម អាជីវកម្មរបស់មូលដ្ឋាន ។

បានានុក្រមគ្រប់គ្រងថ្លៃ

ផ្តើមចេញពីខ្លឹមសារនៃការគ្រប់គ្រងរបស់រដ្ឋ លើការងារថ្លៃដូចខាងលើនាពេលបច្ចុប្បន្ននេះ កំណត់បានានុក្រមគ្រប់គ្រងថ្លៃដូចតទៅ ៖

ក្រុមប្រឹក្សារដ្ឋមន្ត្រី ៖

១ – សំរេចទិសដៅភារកិច្ច គោលនយោបាយថ្លៃ គោលការណ៍ និងវិធីសាស្ត្រកសាងថ្លៃ របបគ្រប់គ្រង និងផែនការថ្លៃ ។

២ – អនុម័តសំរេចគំរោងកែសំរួលថ្លៃក្នុងផែនការឆ្នាំ ។

៣ – អនុម័តសំរេច

ក ថ្លៃឧបករណ៍សំភារៈទំនិញសំខាន់ចាំបាច់ចំពោះផលិតកម្ម និង សាជីវកម្ម ។

១ — សន្ទស្សន៍ថ្លៃទីផ្សារ និង បណ្តាវិធានការរាំងខ្ទប់សន្ទុះកើនឡើងនៃថ្លៃទីផ្សារ ។

៤ — សំរេចថ្លៃបណ្តាផលិតផលសំខាន់ៗ បំផុតនៃខឿនសេដ្ឋកិច្ចដែលរៀបខាង :

ក . ថ្លៃទិញ :

— ស្រូវ

ឈើមូល

ខ - ថ្លៃលក់គ្រឿងឧបករណ៍ :

— មធ្យោបាយដឹកជញ្ជូនទំនិញ : ក្បាលរថភ្លើង ទូរថភ្លើង កប៉ាល់

— ប្រេងឥន្ធនៈ សាំង ដេស្សូ អេស្សង់ ។

ថ្លៃដឹកជញ្ជូនទំនិញតាមផ្លូវគោក ផ្លូវដែក ផ្លូវទឹក និង ផ្លូវអាកាស

— ថ្លៃដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស

— អប្បហារចរាចរខ្ទង់ផ្នែករបស់បណ្តាក្រសួង ។

គ . ថ្លៃលក់រាយ :

— ថាមពលអគ្គិសនី និង ទឹក

— ថ្លៃទិញ ថ្លៃលក់ លោហធាតុ និង ត្បូងថ្មមានតម្លៃនានា

ឃ - អត្រាខ្ទង់ប្រាក់រៀល :

— អត្រាខ្ទង់សំរាប់ការនាំចេញ និង នាំចូល គិតជាប្រាក់រៀលប្រៀបធៀបទៅនឹងប្រាក់រូបិយប័ណ្ណ ដែលក្រសួងហិរញ្ញវត្ថុ និង អគ្គភាពពាក់ព័ន្ធលើកគំរោងស្នើឡើង ។

II- ក្រសួងផែនការមានភារកិច្ច :

— គ្រប់គ្រងថ្លៃក្នុងប្រទេស និងត្រួតពិនិត្យការអនុវត្តថ្លៃរបស់បណ្តាសមាសភាពសេដ្ឋកិច្ចទាំងឡាយ ។

— លើកសំណើជូនក្រុមប្រឹក្សារដ្ឋមន្ត្រីពិនិត្យ សំរេចនូវទិសដៅភារកិច្ច គោលនយោបាយ គោលការណ៍ វិធីសាស្ត្រកសាងថ្លៃ របបគ្រប់គ្រងថ្លៃ និងផែនការថ្លៃ ព្រមទាំងណែនាំអនុវត្តដល់បណ្តាផ្នែក បណ្តាថ្នាក់ បណ្តាអគ្គភាពមូលដ្ឋានទាំងអស់អោយអនុវត្តបានល្អ រាល់សេចក្តីសំរេចថ្លៃរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

— សិក្សាស្រាវជ្រាវ កសាងគំរោងថ្លៃបណ្តាផលិតផលដែលឋិតក្នុងសមត្ថកិច្ចសំរេចរបស់

ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្វែងយល់មតិពីបណ្ដាក្រសួង និង សំណើជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីបណ្ដាគំរោងថ្លៃរបស់ក្រសួងនានា ។

សិក្សាស្រាវជ្រាវបទពិសោធន៍ក្នុង និងក្រៅប្រទេស ដើម្បីកសាងបណ្ដាគោលការណ៍ វិធានការក្នុងដំណាក់កាលនីមួយៗ ។ សំដៅសុក្រិតភាពបែបបទរចនាសម្ព័ន្ធថ្មីក្នុងការគ្រប់គ្រងថ្លៃ ។ កសាងផែនការបណ្ដុះបណ្ដាលកម្មាភិបាលថ្លៃ ដើម្បីឆ្លើយតបនឹងសំណូមពរនៃការគ្រប់គ្រងរដ្ឋអំពីថ្លៃក្នុងសភាពការណ៍ថ្មី ។

— ណែនាំគន្លង និងសំរេចថ្លៃទិញជាក់ស្ដែង ថ្លៃលក់ដុំឧបករណ៍ជាក់ស្ដែង ថ្លៃលក់រាយជាក់ស្ដែងតាមគុណភាព យថាប្រភេទ ចំពោះបណ្ដាផលិតផលទាំងឡាយដែលក្រុមប្រឹក្សារដ្ឋមន្ត្រីបានសំរេចថ្លៃជាគោលរួចមកហើយ ។

- សំរេចថ្លៃបណ្ដាផលិតផលសំខាន់ៗ ដែលរួមមាន ៖

១- ថ្លៃលក់ដុំឧបករណ៍ :

— រថយន្តគ្រប់ប្រភេទ ម៉ាស៊ីនកាណូត , ម៉ាស៊ីនភ្លើង ...

— សំបក និងពោះវៀនកង់រថយន្តនាំចូល

— ឈើមូល

— ឈើអារ

— សត្វសីសទឹក , ហ្វីប្រូស៊ីម៉ង់ត៍ , ស៊ីម៉ង់ត៍នាំចូល

— លោហធាតុគ្រប់ប្រភេទ

— ប្រេងឥន្ធនៈ ប្រេងរំអិល ខ្លាញ់រំអិល ...

— វត្ថុធាតុដើម , ជាតិគីមីគ្រប់ប្រភេទ

— ថ្លៃលក់ – ថ្លៃឈ្នួលផ្ទះ } កម្មសិទ្ធិរដ្ឋ
— ថ្លៃលក់ – ថ្លៃឈ្នួលដី }

២- ថ្លៃលក់រាយ

— ប្រេងកាត

— ស្ករសនាំចូល

- សំឡី កប្បាស , អំបោះសរសៃកប្បាស , អំបោះសរសៃសំយោគនាំចូល

- ឱសថព្យាបាលរោគដែលប្រើប្រាស់ទូលំទូលាយ ដូចជា គីនីន អាស្ពីរីន ប៉្លាមីផង់ ប៉េនីស៊ីលីន តែត្រាស៊ីគ្លីន តេរ៉ាមីស៊ីន ។

– ក្រដាសគ្រប់ប្រភេទ , សៀវភៅសិក្សា ។

III– ក្រសួង - អគ្គនាយកដ្ឋាន :

១ – កសាងបណ្តាគោលនយោបាយថ្លៃ , ពិចារណារិះរកវិធានការទប់ស្កាត់សន្ទុះកើនឡើងនៃថ្លៃទីផ្សារ ផ្ញើជូនក្រុមប្រឹក្សារដ្ឋមន្ត្រី ។

២ – ចាត់តាំងការទទួលពត៌មាន និងផ្តល់ពត៌មាន ព្យាករណ៍អំពីទីផ្សារក្នុងនិងក្រៅប្រទេស អោយដល់បណ្តាមូលដ្ឋានផលិតកម្ម · អាជីវកម្ម និងបណ្តាស្ថាប័នស្រាវជ្រាវ ។

៣ – ត្រួតពិនិត្យការអនុវត្តគោលនយោបាយថ្លៃ កំណត់ថ្លៃអត្រាថ្លៃដែលរដ្ឋណែនាំ ។ តែ លំអ អប់រំអ្នកដែលប្រព្រឹត្តល្មើសនឹងបទវិន័យរបស់ រដ្ឋពីថ្លៃ ។ ដោះស្រាយថ្លៃបណ្តាផលិតផល ទំនិញដែលបានទិញ - លក់តាមថ្លៃស្រុះស្រួល ក្នុងករណីពុំមានការឯកភាពគ្នារវាងអ្នកទិញ និងអ្នកលក់ ។

៤ – កសាងបណ្តាតំរោងថ្លៃនានា (ថ្លៃដើម ថ្លៃទិញ ថ្លៃលក់ដុំឧបករណ៍និងថ្លៃលក់រាយ) នៃបណ្តាផលិតផល ដែលស្ថិតក្នុងសមត្ថកិច្ចសំរេចថ្លៃរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ និងសាមីក្រសួងគ្រប់គ្រង ។

៥ – សំរេចថ្លៃទិញ ថ្លៃលក់ដុំឧបករណ៍ ថ្លៃលក់រាយតាមគុណភាព យថាប្រភេទ តាមតំបន់ . . . ចំពោះបណ្តាផលិតផលដែលក្រុមប្រឹក្សារដ្ឋមន្ត្រី ឬ ក្រសួងផែនការ បានសំរេចថ្លៃជាគោលរួចហើយ ។

៦ – សំរេចថ្លៃបណ្តាផលិតផល កសិកម្ម រុក្ខកម្ម ជលផល ដែលមានសំណូមពរប្រើប្រាស់ទូលំទូលាយបណ្តាវត្ថុធាតុដើមសំរាប់ឧស្សាហកម្ម ផលិតផលសំរាប់នាំចេញ ដែលមិនស្ថិតនៅក្រោមសិទ្ធិសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ឬ ក្រសួងផែនការ ។

ក្រសួងផែនការត្រូវឯកភាពជាមួយបណ្តាក្រសួង ដើម្បីកំណត់ឈ្មោះបណ្តាផលិតផលដែលស្ថិតក្នុងសមត្ថកិច្ចសំរេចថ្លៃរបស់បណ្តាក្រសួង ។

បណ្តាសេចក្តីសំរេចថ្លៃត្រូវផ្ញើមក - ក្រសួងផែនការ គណៈកម្មាធិការប្រជាជនខេត្ត- ក្រុង ភាគីទី ។

បណ្តាក្រសួងអាចប្រគល់សិទ្ធិអោយបណ្តាក្រុមហ៊ុន សម្ព័ន្ធសហគ្រាស ក្រោមឱវាទផ្ទាល់ កំណត់កំរិតថ្លៃជាក់ស្តែង តាមយថាប្រភេទខ្នាត និងគុណភាពជាក់ស្តែង ចំពោះផលិតផលមួយចំនួនដែលមានសេចក្តីសំរេចថ្លៃរបស់ក្រសួងផែនការ ឬ របស់សាមីក្រសួងរួចហើយ និងប្រគល់

អោយសំរេចថ្លៃ បណ្តាផលិតផលទាំងឡាយណា ដែលមិនស្ថិតក្នុងសេចក្តីចុះសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងបណ្តាក្រសួង ក្រោយពីបានសំរបសំរួលឯកភាពជាមួយមូលដ្ឋាន និងអង្គភាពផលិតកម្មអាជីវកម្មរួចហើយ ។ ថ្លៃបណ្តាផលិតផលទាំងនោះ ត្រូវធានាដល់ផលិតកម្មអាជីវកម្មចរាចរបញ្ចេញលក់ និងមានប្រសិទ្ធភាពសេដ្ឋកិច្ច ប៉ុន្តែមិនត្រូវបង្កើនថ្លៃ ឬ ប៉ាន់ថ្លៃតាមទំនើងចិត្តដោយឥតសមហេតុផល ដើម្បីរកកម្រៃអោយបានច្រើនជាដាច់ខាត ។ បណ្តាសេចក្តីសំរេចថ្លៃត្រូវផ្ញើមកសាម៉ីក្រសួង ក្រសួងផែនការ បណ្តាគណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ពាក់ព័ន្ធ ។

ចំពោះថ្លៃឈ្នួលដឹកជញ្ជូន ផលិតផលឧស្សាហកម្ម សិប្បកម្មគឺអាស្រ័យតួភាគីទាំងពីរធ្វើការព្រមព្រៀងកំណត់ថ្លៃ ។

IV - គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង

១ - ត្រួតពិនិត្យបណ្តាអង្គភាពផលិតកម្ម អាជីវកម្ម សេវាកម្មដែលធ្វើសកម្មភាពនៅក្នុងមូលដ្ឋានរបស់ខ្លួនដោយអនុវត្តត្រឹមត្រូវគោលនយោបាយថ្លៃ កំរិតថ្លៃ និង តម្រាថ្លៃរបស់រដ្ឋ ។

ចាត់វិធានការអប់រំកែតំរូវអ្នកប្រព្រឹត្តល្មើសបទវិន័យរបស់រដ្ឋអំពីថ្លៃ តាមការកំណត់របស់រដ្ឋ។

២ — ដោះស្រាយថ្លៃបណ្តាផលិតផលដែលបានទិញ - លក់តាមការស្រុះស្រួលហើយដែលមិនធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ទាំងអ្នកទិញ និង អ្នកលក់ ។

៣ - ចាត់តាំងវេណនដែលបណ្តាផ្នែកសេដ្ឋកិច្ចក្នុងមូលដ្ឋានរបស់ខ្លួន អោយមានវិធានការគ្រប់គ្រងទីផ្សារ និង ទប់ស្កាត់សន្ទុះកើនឡើងនៃថ្លៃទីផ្សារ ។

៤ - ចាត់តាំងការយកព័ត៌មានថ្លៃទីផ្សារ មូលដ្ឋាន និងរាយការណ៍ជូនមជ្ឈិម ។

V - បណ្តាអង្គភាពផលិតកម្ម អាជីវកម្ម សេវាកម្ម ស្វ័យភិបាលសេដ្ឋកិច្ច

ត្រូវប្រឹងប្រែង បន្តអនុវត្ត សារាចររបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៣ សារចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ១៩៨៨ ស្តីពីសិទ្ធិម្ចាស់ការផលិតកម្ម អាជីវកម្មរបស់សហគ្រាសឧស្សាហកម្មរដ្ឋ អោយមានប្រសិទ្ធិភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ១៦/១ វិច្ឆិកា ឆ្នាំ ១៩៩០

សេចក្តីសំរេចលេខ ១៦៣ សសរ

ស្តីពីថ្លៃប្រេង ឥន្ធនៈ

ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញ រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីរចនាការងារ និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលបានប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- យោងសេចក្តីសំរេចរបស់គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ១៨ ខែតុលា ឆ្នាំ១៩៩០
- តាមសំណើរបស់ក្រសួងផែនការ

សំរេច

ប្រការ ១ : កំណត់ថ្លៃលក់ប្រេងសាំងសំរាប់ក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ គ.ឋ ខ្សែជួរ ការងារដឹកជញ្ជូនផ្លូវ-ស្ពានដោយមន្ទីរសាធារណៈ និង ការដ្ឋានចក្រ ឥត ឡើងគុណមួយលីត្រ ។

ប្រការ ២ : កំណត់ថ្លៃលក់ប្រេងឥន្ធនៈសំរាប់បំរើវិស័យរដ្ឋ មានដូចខាងក្រោម :

ល.រ	ប្រភេទប្រេងឥន្ធនៈ	ឯកតា	ថ្លៃលក់
១	ប្រេង ដេអូ	១ លីត្រ	៦៥
២	ប្រេង អេហ្វ អូ		៤៣

ប្រការ ៣ : ផ្អែកតាមកំរិតថ្លៃក្នុងប្រការ ១ និងប្រការ ២ នៃសេចក្តីសំរេចនេះ ក្រសួងផែនការមានភារកិច្ចកំណត់ថ្លៃលក់ប្រេង សំរាប់ប្រើប្រាស់ខុសសញ្ញាផ្សេងទៀត និងប្រេងរំអិលខ្លាញ់រំអិលព្រមទាំងណែនាំការអនុវត្តន៍ជាក់ស្តែង ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានន័យផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន។

សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩១ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ចាន់ សុខ

៣ _ សេចក្តីជូនដំណឹង

ភ្នំពេញ, ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩០

សេចក្តីជូនដំណឹងលេខ ៤៩ សជណ

ក្រុមប្រឹក្សារដ្ឋមន្ត្រី

ជំរាបមក

សមមិត្តរដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នជុំវិញមជ្ឈិម

សមមិត្តប្រធានគណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង

កម្មវត្ថុ : ការអនុវត្តគោលនយោបាយ ចំពោះគ្រួសារជនពលី មរណៈ ជនពិការ និងគ្រួសារកងទ័ព ។

យោង : សារាចរណែនាំរបស់គណៈលេខាធិការមជ្ឈិមបក្ស លេខ ១៦២ ស.រ.ន យេ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ១៩៩០ ។

- របាយការណ៍ស្តីពីការអនុវត្តគោលនយោបាយចំពោះគ្រួសារយោធិន ពលី មរណៈ និងយោធិនពិការ ៈ ឈើ ៩ ខែ ដើមឆ្នាំ ១៩៩០ របស់គណៈកម្មាធិការណែនាំដោះស្រាយគោលនយោបាយចំពោះគ្រួសារយោធិន ពលី មរណៈ និងយោធិនពិការ..ឈឺ លេខ ០៥ រប ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩០ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ដើម្បីឆ្លើយតបនូវគុណូបការៈ ចំពោះកម្មាភិបាល យុទ្ធជន ប្រជាជន ដែលត្រូវ ពលី របួស ពិការ ក្នុងបុព្វហេតុការពារ និង កសាងមាតុភូមិ ស្របតាមការយកចិត្តទុកដាក់របស់បក្ស-រដ្ឋ ។ ផ្អែកតាមលទ្ធផល ក្នុងការអនុវត្តការងាររបស់ស្ថាប័នក្រសួងមន្ទីរ និងមូលដ្ឋាន ខេត្ត - ក្រុង ក្នុងរយៈកាលកន្លងមក ពិសេសមានអង្គភាពក្រសួង មន្ទីរ ខេត្ត - ក្រុង មួយចំនួនពុំទាន់អនុវត្តបានល្អ តាមខ្លឹមសារ សេចក្តីសំរេច សេចក្តីណែនាំ និងបណ្តាលិខិត បទដ្ឋានរបស់បក្ស រដ្ឋ ស្តីពីរបបគោលនយោបាយចំពោះ គ្រួសារ

ជនពលី មរណៈ ជនពិការ និងគ្រួសារកងទ័ព ក្រុមប្រឹក្សារដ្ឋមន្ត្រី សូមធ្វើការណែនាំលើកនូវ ការអនុវត្តដូចខាងក្រោមនេះ :

១. គ្រប់ក្រសួង ស្ថាប័នចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលមានការពាក់ព័ន្ធ ត្រូវណែនាំត្រួតពិនិត្យឡើងវិញ បណ្តាអង្គភាពជំនាញចំណុះក្រសួងស្ថាប័នផ្ទាល់ និងខ្សែរយៈជំនាញនៅតាមបណ្តាខេត្ត-ក្រុង ក្នុងការអនុវត្តគោលនយោបាយ ខាងលើកន្លងមក ជំរុញចាត់តាំងអនុវត្តអោយបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ នូវសារាចរ សេចក្តីសំរេច ដែលពាក់ព័ន្ធនិងគោលនយោបាយចំពោះគ្រួសារជនពលី មរណៈ ជនពិការ និងគ្រួសារកងទ័ពដែលបានធ្វើការផ្សព្វផ្សាយរួចមកហើយ ។

២- គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវណែនាំចាត់តាំងត្រួតពិនិត្យ បណ្តាអង្គភាពជំនាញចំណុះអោយខេត្ត-ក្រុង ខ្លួនផ្ទាល់ នូវបណ្តាការងារសំខាន់ៗ មួយចំនួនដូចតទៅ :

ក- ពង្រឹងពង្រីកតួនាទី ភារកិច្ច និង ប្រសិទ្ធភាពរបស់គណៈកម្មការណែនាំដោះស្រាយគោលនយោបាយ ចំពោះគ្រួសារយោធិនពលី មរណៈ និង យោធិនពិការ ឈឺ នៅតាមខេត្តក្រុង អោយមានសកម្មភាពខ្លាំងក្លា សំដៅធ្វើជាផែនគ្រឹះ នៃការជំរុញអនុវត្តការងារគោលនយោបាយ ។

ខ- ជំរុញការស្រង់ស្ថិតិមុខសញ្ញា ជនពលី ពិការ មរណៈ គ្រប់ជំនាន់ អោយបានត្រឹមត្រូវច្បាស់លាស់ និងឆាប់រហ័សបំផុត តាមសេចក្តីណែនាំ និងលិខិតបទដ្ឋានដែលបានកំណត់ ។

គ- ជំរុញសកម្មភាព ក្រុមប្រឹក្សាវាយតម្លៃប្រភេទ ថ្នាក់ពិការរបស់ខេត្ត-ក្រុង ក្នុងការចាត់តាំងវាយតម្លៃប្រភេទថ្នាក់ពិការអោយបានទាន់ពេលវេលា ។

ឃ- ជំរុញការងារផ្ទេរទទួល យុទ្ធជនពិការ គ្រួសារជនពលី មរណៈ ពីអង្គភាពយោធា នគរបាល មកមន្ទីរយុទ្ធជនពិការ-សង្គមកិច្ច ដើម្បីបន្តគ្រប់គ្រង និងដោះស្រាយរបបគោលនយោបាយ ។

ង- ជំរុញការងារស្តារលទ្ធភាពពលកម្ម បណ្តុះបណ្តាលវិជ្ជាជីវៈ មុខរបរជូនដល់ជនពិការអោយបានសមស្រប ។

ច- ជំរុញការងារសង់មណ្ឌល ចិញ្ចឹមយុទ្ធជនពិការ អោយបានឆាប់រហ័ស និងធានាការគ្រប់គ្រង ចិញ្ចឹមថែរក្សាអោយបានល្អ ។

ឆ- ចាត់តាំងត្រួតពិនិត្យឡើងវិញ ការដោះស្រាយរបបគោលនយោបាយ ជូនមុខសញ្ញា

ពលី ពិការ មរណៈ និងគ្រួសារ បំបាត់អោយបានបាតុភាពអសកម្ម គឺបកេងរបបគោលនយោបាយរបស់មុខសញ្ញា តាមមធ្យោបាយបច្ចេកទេស ។

ជ- ចាត់តាំងក្រុមចំរុះ ដែលមានសមាសភាពផ្នែកយោធា នគរបាល និងយុទ្ធជន ពិការ សង្គមកិច្ច ក្នុងការប្រមូលផ្តុំគ្រប់គ្រង អប់រំ យុទ្ធជនពិការ និងជនខិលខូច ដែលបន្លំខ្លួនជាយុទ្ធជនពិការបង្កបាតុភាពអសកម្ម នៅតាមទីសាធារណៈ ស្រាវជ្រាវរកលិខិតស្នាមអត្តសញ្ញាណ និងមានវិធានការដោះស្រាយសមស្របទាន់ពេលវេលា ។

ឈ- យកចិត្តទុកដាក់ ដោះស្រាយរបបអត្ថរ និងរបបផ្គត់ផ្គង់ផ្សេងៗ ជូនគ្រួសារកម្មាភិបាល យុទ្ធជន សមរភូមិមុខ យុទ្ធជនពិការ គ្រួសារពលី មរណៈ អោយបានល្អឆាប់រហ័ស និងទាន់ពេលវេលា សមស្របតាមសារាចររបស់បក្ស និងរដ្ឋដែលបានដាក់ចេញ ។

អាស្រ័យហេតុនេះ ស្នើសមមិត្តរដ្ឋមន្ត្រី ប្រធានស្ថាប័ន និង គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត - ក្រុង ចាត់ចែងជំរុញអនុវត្តរបបគោលនយោបាយខាងលើ ដោយសហការជាមួយ ក្រសួងយុទ្ធជនពិការ . សង្គមកិច្ចអោយទទួលបាន នូវ លទ្ធផលកាន់តែល្អប្រសើរ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ចុំ ៩០

សហគ្រាសសម្ព័ន្ធរោងពុម្ព
បោះពុម្ពនៅរោងពុម្ពសុខាភិបាល
លើកទី ១ ចំនួន ៩.០០០ ច្បាប់